អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តីបានទទួលលិខិតមួយច្បាប់ពីលោក កាំង ហ្កេកអ៊ាវ (ហៅ "ឌុច") ស្នើសុំដកសហមេធាវីបរទេសរបស់គាត់ Francois Roux ។

មូលហេតុសម្រាប់ការណែញសហមេធាវី មានចែងនៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ។ មាត្រា ៧.២ ចែងថា:

> "*ការផ្លាស់ប្តូរមេធាវី:* ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទអាចដាក់ពាក្យទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សុំផ្លាស់ប្តូរសហមេធាវីទាំងពីរ ឬសហមេធាវីណាម្នាក់ក្នុងចំណោមពួកគេ ។ ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អាចត្រូវបានអនុញ្ញាតឲ្យផ្លាស់ប្តូរសហមេធាវី តែនៅក្នុងករណីពិសេសប៉ុណ្ណោះ" ។

អង្គភាពគាំពារការការពារក្តីបានពិនិត្យវិធីសាស្រ្តដែលអនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬ តុលាការឧក្រិដ្ឋកម្មកូនកាត់ដទៃទៀត ។ ភាគច្រើនតុលាការទាំងនេះបានទទួលយកសំណើរបស់ជនជាប់ចោទសុំដកមេធាវីការពារក្តី នៅពេលការបាត់បង់ទំនុកចិត្តមានពិតប្រាកដមែន និងលុះត្រាតែការសុំដកមេធាវីមិនបង្កឲ្យមានការពន្យាដំណើរការនីតិវិធីដោយមិនត្រឹមត្រូវ ឬ រារាំងដល់ដំណើរការនីតិវិធី ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) នៅក្នុងករណី *Tadic* ជនជាប់ចោទក៏បានស្នើសុំដកមេធាវីការពារក្តីរបស់គាត់បន្ទាប់ពីសវនាការបានបញ្ចប់ ប៉ុន្តែនៅមុនការចេញសាលក្រម ។ នៅក្នុងករណីនេះតុលាការបានយល់ព្រមលើសំណើដោយឈរលើមូលដ្ឋានថា: "សវនាការរបស់ជនជាប់ចោទបានបញ្ចប់ ហើយកំពុងរង់ចាំការចេញសាលក្រម ហើយដូច្នេះ ការដកមេធាវីការពារក្តីនឹងមិនបង្កឲ្យមានការពន្យាដំណើរនីតិវិធីបច្ចុប្បន្ននោះទេ" ។

Original EN: 00527483-00527484

នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តីបានយល់ព្រមលើសំណើរបស់លោក កាំង ហ្គេកអ៊ាវ និង បានចេញសេចក្តីសម្រេចផ្នែករដ្ឋបាលដែលមានខ្លឹមសារដូចខាងក្រោមៈ

1. *អង្គភាពគាំពារការការពារក្តីបានយល់ព្រមលើសំណើរបស់លោក កាំង ហ្គេកអ៊ាវ សុំដកសហមេធាវីបរទេសរបស់គាត់ លោក Roux ។*
2. *នៅក្នុងការធ្វើសេចក្តីសម្រេចនេះ អង្គភាពគាំពារការការពារក្តីបានកត់សំគាល់ដូចខាងក្រោមៈ*
   *ក. ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថាការបាត់បង់ទំនុកចិត្តរបស់លោក កាំង ហ្គេកអ៊ាវ គឺមិនពិតនោះទេ ។*
   *ខ. ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថា សំណើសុំដកមេធាវីការពារក្តីមានចេតនារារាំងដល់ដំណើរការនីតិវិធីដែរ ។*
   *គ. ការដកលោក Roux នៅដំណាក់កាលនេះនឹងមិនបង្កឲ្យមានការពន្យាដំណើរការនីតិវិធីដោយមិនត្រឹមត្រូវដែរ ។*
   *ឃ. ការបាត់បង់ទំនុកចិត្តបង្កើតឲ្យមានករណីពិសេស ។*
3. *សេចក្តីសម្រេចនេះមិនមែនជាការគាំទ្រដល់មូលហេតុនៃការបាត់បង់ទំនុកចិត្ត ដែលត្រូវបានលើកឡើងនៅក្នុងសំណើរបស់លោក កាំង ហ្គេកអ៊ាវ នោះទេ ។ នៅក្នុងកាលៈទេសៈនេះ វាមិនចាំបាច់ទទួលយក ឬ បដិសេធមូលហេតុទាំងអស់ខាងលើនេះ ។*
4. *អង្គភាពគាំពារការការពារក្តីសូមឲ្យអង្គជំនុំជម្រះសាលាដំបូងយល់ព្រមលើការដកលោក Roux ជាសហមេធាវីបរទេសរបស់លោក កាំង ហ្គេកអ៊ាវ ។*

នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានឃើញការស្នើសុំដកលោក Roux ជាសហមេធាវីបរទេសរបស់លោក កាំង ហ្គេកអ៊ាវហើយ ។

សហមេធាវីជាតិរបស់គាត់ លោក ការ សាវុត្ថ នឹងបន្តការពារលោក កាំង ហ្គេកអ៊ាវ ទៅទៀត ។ អង្គភាពគាំពារការការពារក្តីនឹងមិនពិចារណាលើការចាត់តាំងសហមេធាវីទីពីរ ដើម្បីជំនួសលោក Roux ទេ រហូតទាល់តែក្រោយការចេញសាលក្រម ។

Original EN: 00527483-00527484

អង្គភាពគាំពារការការពារក្ដីសូមអរគុណដល់លោក Roux និងក្រុមមេធាវីអន្តរជាតិរបស់គាត់ចំពោះការចូលរួមវិភាគយ៉ាងសំខាន់របស់ពួកគេ នៅក្នុងសំណុំរឿង ០០១ និងសូមអរគុណផងដែរដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

Richard J Rogers
**ប្រធានអង្គភាពគាំពារការការពារក្ដី**

Original EN: 00527483-00527484